**ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់**
**ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ី ប៉ាស៊ីហ្វិក៖**
**ការអភិវឌ្ឍជំនាញផ្នែកបរិស្ថាន**
**ការបណ្តុះបណ្តាលគ្រូបង្គោល**
**ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧**
**ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា**

# វគ្គទី ៥៖ ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន

## លំហាត់សម្រាប់ការបង្រៀន (ការគ្រប់គ្រងកាកសំណល់រឹង)

### ស្ថានភាពជាក់ស្តែង

ទីក្រុងយ៉ុងឡុងមានកន្លែងចាក់សំរាមចំហរមួយកន្លែង (ឬកន្លែងចាក់សំរាម) ដែលត្រូវបានប្រើប្រាស់សម្រាប់កាកសំណល់រឹងរបស់ក្រុងដែលប្រមូលបានដោយក្រុមហ៊ុន Waste Away ជាក្រុមហ៊ុនដែលបានបង្កើតឡើងក្នុងឆ្នាំ 2007 ។ វាជាក្រុមហ៊ុនប្រមូលសំរាមដ៏សំខាន់នៅក្នុងទីក្រុងយ៉ុងឡុង ហើយបានចុះកិច្ចសន្យាជាមួយរដ្ឋបាលថ្នាក់ខេត្តដើម្បីប្រមូលកាកសំណល់តាមផ្ទះ និង កន្លែងធ្វើអាជីវកម្មរយៈពេល 50 ឆ្នាំ។

Waste Away បានបង្កើតតំបន់ចាក់សំរាមរបស់ខ្លួននៅជិតភូមិ Long Pi ចម្ងាយ 25 គ.ម ពីក្រុងយ៉ុងឡុងក្នុងឆ្នាំ 2009 ។ ក្រុមហ៊ុនបានជីករណ្តៅចំនួនបីធំៗ ដែលមានជម្រៅរហូតដល់ 20 ម៉ែត្រ ដែលប្រើសម្រាប់ចាក់កាកសំណល់ដែលបានប្រមូលទុកក្នុងរណ្តៅនេះ ។ កាកសំណល់មិនត្រូវបានបែងចែកប្រភេទសំរាមមុនចាក់ចូលក្នុងរណ្តៅ។ ក្រៅពីកាកសំណល់តាមផ្ទះ និងកន្លែងធ្វើអាជីវកម្ម ក្នុងនោះក៏មានកាកសំណល់ឧស្សាហកម្ម និង វេជ្ជសាស្ត្របន្តិចបន្តួចដែរ។



កន្លែងចាក់សំរាមបានទាក់ទាញសហគមន៍ដែលមានមនុស្សប្រមាណ 200 នាក់ រស់នៅជិតនោះឱ្យមករើសរបស់របរពីសំរាមដែលគេអាចលក់បាន ដូចជា៖ ធុងប្លាស្ទិច កំប៉ុង និងកាកសំណល់អាហារជាចំណីរបស់សត្វជ្រូក។ សកម្មភាពរបស់ពួកគេអាចប្រឈមនឹងផលប៉ះពាល់ដល់សុខភាពដ៏ធ្ងន់ធ្ងរដោយសារអាហារដែលមានជាតិពុល ឧស្ម័នពុល និងសម្ភារដែលមានគ្រោះថ្នាក់ មានដូចជា៖ ជំងឺគ្រុនពោះវៀន ជំងឺអាសន្នរោគរលាកពោះវៀន និងរាកមួល។ ពួកគេក៏ប្រឈមនឹងហានិភ័យនៃការរងរបួសលើរូបរាងកាយដោយសារការប្រើប្រាស់គ្រឿងចក្រធំៗដែលនៅជិតពួកគេ។



នៅឆ្នាំ 2014 ប្រជាពលរដ្ឋនៅក្នុងភូមិ Long Pi បានតវ៉ាទៅក្រសួងបរិស្ថាន អំពីហេតុប៉ះពាល់បរិស្ថាននៅកន្លែងចាក់សំរាម។ ជាពិសេស ពួកគេបានសម្តែងការព្រួយបារម្ភ អំពីការបូមទឹកចេញពីកាកសំណល់ពីកន្លែងចាក់សំរាម ដោយក្រុមហ៊ុន Waste Away ទៅក្នុងវាលស្រែដែលនៅជិតកន្លែងចាក់សំរាមនោះ និងមានការចម្លងមេរោគនៅក្នុងប្រឡាយទឹកដែលនៅជុំវិញនោះ។ ពួកគេក៏បានតវ៉ាថាសំរាមពីកន្លែងនោះបានចេញមកក្នុងស្រែរបស់ពួកគេដោយសារតែការទុកដាក់មិនបានសមស្របនៅទីតាំងចាក់សំរាមនោះ។ ពួកគេក៏បានលើកឡើងថាសត្វស្លាប និងសត្វពាហនៈ ដូចជាៈ គោ និងក្របី បានទទួលរងគ្រោះ ដោយសារដោយសារស៊ីកំទេចកំទីកាកសំណល់ពីកន្លែងនោះ និងផឹកទឹកនៅលើដីដែលមានជាតិពុល។ ជាលទ្ធផល ក្រុមហ៊ុន Waste Away ត្រូវបានណែនាំដោយ ក្រសួងបរិស្ថានឱ្យបញ្ឈប់ការបង្ហូរទឹកពីកន្លែងនោះ និងសាងសង់របងនៅជុំវិញកន្លែងចាក់សំរាមដើម្បីការពារកុំឱ្យកាកសំណល់ចេញពីកន្លែងនោះ។

ថ្វីបើក្រុមហ៊ុន Waste Away បានអនុវត្តវិធានការទាំងនេះក្នុងកំឡុងឆ្នាំ 2015 កន្លែងចាក់សំរាមនៅតែខ្វះប្រព័ន្ធសមស្របសម្រាប់ការប្រមូល និងធ្វើប្រព្រឹត្តិកម្មទឹកចេញពីកាកសំណលសំរាម។ វាពឹងផ្អែកលើបរិមាណដីឥដ្ឋក្នុងដីដើម្បីទប់ស្កាត់ការបំពុលទឹកក្រោមដី និងការបំពុលដី។ គ្មានការការពាររៀបចំបង្ហាប់ជាថ្នាក់ៗក្នុងការចាក់កាកសំណល់ ។ ស្រះដែលនៅជុំវិញមានពណ៌ខ្មៅ និងមានក្លិនមិនល្អ ហើយអណ្តូងមួយចំនួននៅជិតទីតាំងចាក់សំរាមនេះត្រូវបានបំពុល។ វាក៏មានបញ្ហារីកសាយភាយឧស្ម័នមេតានកាន់តែច្រើនឡើង ដែលបានកើតចេញពីកាកសំណល់ដែលបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរអាចកើតឡើងនូវការផ្ទុះនៅទីតាំងនោះ។



បន្ទាប់ពីមានការតវ៉ាពីប្រជាពលរដ្ឋក្នុងភូមិរួចមក ក្រុមហ៊ុន Waste Away ត្រូវបានណែនាំដោយក្រសួងបរិស្ថាននៅឆ្នាំ 2016 ឱ្យដាក់ឯកសារត្រួតពិនិត្យបរិស្ថាននៅទីតាំងនោះទៅក្រសួង។ គោលបំណងនៃការដាក់ឯកសារត្រួតពិនិត្យនេះ គឺដើម្បីកំណត់ពីហេតុប៉ះពាល់បរិស្ថានដែលកំពុងកើតមាន និងដើម្បីស្នើឱ្យមានវិធានការផ្តល់សំណង ។ បន្ទាប់ពីធ្វើការត្រួតពិនិត្យនេះរួច ក្រសួងបរិស្ថានបានណែនាំឱ្យក្រុមហ៊ុន Waste Away ចាត់វិធានការដើម្បីៈ (1) ធ្វើប្រព្រឹត្តិកម្មទឹកដែលចេញពីកាកសំណល់សំរាមនៅទីតាំងនោះ (2) រៀបចំប្រព័ន្ធប្រមូល

ឧស្ម័នមេតាន (3) កាត់បន្ថយការបំពុលដី (4) កាត់បន្ថយការចេញកាកសំណល់ទៅលើវាលស្រែនៅជុំវិញ។ និង (5) ការពារមិនឱ្យចូលទៅដល់គំនរកាកសំណល់ដោយសត្វគោ ជ្រូក និងសត្វផ្សេងៗទៀត។



ក្រោយមកនៅឆ្នាំ 2016 ក្រុមហ៊ុន Waste Away បានរៀបចំផែនការដើម្បីបង្កើតស្រះសម្រាប់ធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់ និងទឹកចេញពីកាកសំណល់សំរាមដើម្បីគ្របលើស្រទាប់របស់កាកសំណល់ដោយប្រើដីឥដ្ឋនៅពេលចាក់បំពេញពីលើ ហើយដំឡើងប្រព័ន្ធប្រមូលឧស្ម័នមេតាន។ ដើម្បីអនុវត្តគម្រោងទាំងនេះ ក្រុមហ៊ុនត្រូវតែបិទមិនឱ្យអ្នករើសសំរាមចូលទៅកាន់ទីតាំងចាក់សំរាមបាន។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលក្រុមហ៊ុនព្យាយាមរារាំងមិនឱ្យចូលទៅទីតាំងនោះដោយអ្នករើសសំរាមនៅក្នុងខែ មីនា ឆ្នាំ 2017 បង្កឱ្យមានការតវ៉ាយ៉ាងខ្លាំង។ ក្រោយមកទៀត ក្រុមហ៊ុនត្រូវបានអាជ្ញាធរអាជ្ញាធរខេត្តជំរុញឱ្យបន្តអនុញ្ញាតឱ្យអ្នករើសសំរាមចូលទៅកាន់ទីតាំងចាក់សំរាមនោះបានទោះបីជាមានគ្រោះថ្នាក់ដល់សុខភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ដើម្បីឱ្យពួកគេអាចបន្តរកប្រាក់ចំណូលពីសកម្មភាពរបស់ពួកគេ។

ជាលទ្ធផល ក្រុមហ៊ុន Waste Away បាននិយាយថាដោយសារតែរដ្ឋបាលថ្នាក់ខេត្តជំរុញក្រុមហ៊ុនឱ្យអនុញ្ញាតអ្នករើសសំរាមបន្តចូលទៅទីតាំងចាក់សំរាមនោះ ក្រុមហ៊ុននេះនឹងបោះបង់ផែនការរបស់ខ្លួនក្នុងការកែលម្អបរិស្ថាននៅទីតាំងនោះ ហើយក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការនៅកន្លែងចាក់សំរាមនោះដូចបានធ្វើកន្លងមក។

 

**សូមពិចារណាសំណួរដូចខាងក្រោម៖**

ឧបមាថាអ្នកត្រូវបានគេស្នើឱ្យផ្តល់យោបល់ផ្នែកច្បាប់ដល់ក្រសួងបរិស្ថាន អំពីជម្រើសផ្នែកច្បាប់ដែលអាចផ្តល់ជូនដើម្បីដោះស្រាយបញ្ហាបរិស្ថានដែលកំពុងបន្តកើតឡើងនៅកន្លែងចាក់សំរាម និងដោះស្រាយជម្លោះជាមួយអ្នករើសសំរាម។ សូមពិចារណាសំណួរដូចតទៅ៖

1. តើមានច្បាប់សំខាន់ៗអ្វីត្រូវបានដាក់ចេញដោយ ក្រសួងបរិស្ថាន សម្រាប់គ្រប់គ្រងបញ្ហាបំពុលបរិស្ថាននៅកន្លែងចាក់សំរាម? តើមានបទដ្ឋានអ្វីខ្លះ ទាក់ទងនឹងគុណភាពទឹក និងដី ដែលត្រូវអនុវត្តចំពោះការបញ្ចេញកាកសំណល់ពីកន្លែងចាក់សំរាមស្របតាមច្បាប់នេះ?
2. តើក្រសួងបរិស្ថានអាចចាត់វិធានការរដ្ឋបាល ឬច្បាប់អ្វីខ្លះមកលើក្រុមហ៊ុន Waste Away ចំពោះការខកខានមិនបានអនុវត្តសកម្មភាពដែលបានណែនាំដោយក្រសួងនៅឆ្នាំ 2016 (និងមានក្នុងផែនការដោះស្រាយដែលបានបង្កើតឡើងដោយក្រុមហ៊ុននៅក្នុងឆ្នាំ 2016)?
3. តើក្រសួងអាចចាត់វិធានការអ្វីខ្លះដើម្បីទប់ស្កាត់ការបញ្ចេញកាកសំណល់វេជ្ជសាស្ត្រ និងឧស្សាហកម្មនៅ កន្លែងចាក់សំរាម?
4. តើត្រូវចាត់វិធានការអ្វីខ្លះ និងដោយនរណាខ្លះទាក់ទងនឹងតម្រូវការរបស់អ្នករើសសំរាមដែលត្រូវបានអនុញ្ញាតឱ្យចូលទៅកន្លែងចាក់សំរាមនោះ?